# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ ក្រោមប្រធានបទ ពលរដ្ឋខ្មែរក្នុងប្រទេសកម្ពុជាគប្បីមានសម្បជញ្ញៈ ប្រើសិទ្ធិរបស់ខ្លួនឲ្យស្រប តាមឆន្ទៈរបស់ខ្លួនហើយ ។

website : www.hoksavann.org

ថ្ងៃទី២១ វិច្ឆិកា ២០០៦

ប្រជាពលរដ្ឋក្នុងប្រទេសប្រជាធិបតេយ្យ ដែលមានការយល់ដឹងខ្ពស់នូវសិទ្ធិរបស់ខ្លួន តែងតែបញ្ចេញមតិស្របតាមឆន្ទៈរបស់ខ្លួន នៅគ្រប់ការបោះឆ្នោតជ្រើសរើសតំណាងជាតិ មានការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រជាដើម ។ ការអនុវត្តន៍បែបនេះមានជោគជ័យដោយសារប្រព័ន្ធច្បាប់នៃប្រទេសទាំងនោះ បានបើកសិទ្ធិឲ្យប្រជាពលរដ្ឋពេញបរិបូរណ៍ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនជាពលរដ្ឋ ដោយគ្មានការទិញសន្លឹកឆ្នោត ឬដោយការគំរាមកំហែងអ្វីឡើយ ។ ក្រឡេកមើលប្រទេសកម្ពុជា ស្ទើរតែគ្រប់អង្គការឯករាជ្យនៅក្នុងប្រទេសនិងអន្តរជាតិ តែងតែចោទប្រទេសកម្ពុជាថា ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ពុំមានសេរីនិងយុត្តិធម៌ឡើយ ។ មិនយុត្តិធម៌តាំងពីការចុះឈ្មោះ ការឃោសនា ពេលបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផល ។ ប្រទេសកម្ពុជាបានឆ្លងផុតពីសង្គ្រាម និងចេញពីរបបកុម្មុយនិស្តផ្តាច់ការ ហើយនាំគ្នាហាត់រៀនប្រើរបបប្រជាធិបតេយ្យសេរីពហុបក្ស ។ របបថ្មីនេះនៅក្មេងខ្ចីពុំទាន់រឹងដៃរឹងជើងនៅឡើយ បានជាគណបក្សទាំងនោះតែងមានទំនាស់គ្នា ជាពិសេសគណបក្សអ្នកកាន់អំណាចបច្ចុប្បន្ន ដែលជាអតីតគណបក្សកុម្មុយនិស្តនិយមវៀតណាម ដែលអ្នកសង្កេតការណ៍ឯករាជ្យបានចោទថា ជាគណបក្សប្រើល្បិចអាក្រក់ជាងគេ មានលួចប្រហារជីវិតអ្នកប្រឆាំងតាមបែបកុម្មុយនិស្តជាដើម ។ចំណែកគណបក្សក្រៅពីនេះ គិតតែពីហែកហួរគ្នាឯងដណ្តើមអំណាចគ្នានិងច្រណែនបក្សដទៃ ដែលមានគោលបំណងដូចគ្នានៅចំពោះមុខគូប្រជែង ។

តើប្រជាពលរដ្ឋខ្មែរត្រូវបោះឆ្នោតឲ្យបុគ្គលប្រភេទណា ? បើនិយាយអំពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ជនជាតិខ្មែរត្រូវបោះឆ្នោតឲ្យតំណាងរាស្ត្រនៃគ

ណាបក្សណាដែលមានសមត្ថភាព ហើយបំរើខ្មែរ មិនបំរើបរទេស មិនមានបរទេសនៅពីក្រោយ មានកំនិតជាតិនិយម ភោពឆន្ទៈប្រជាពលរដ្ឋ គោរពច្បាប់ជាតិ និងច្បាប់អន្តរជាតិ បំបាត់ភាពក្រីក្រ បំបាត់អំពើពុករលួយ ជាពិសេសរក្សាបូរណភាពទឹកដីមិនឲ្យបាត់បង់ បង្កើតក្រសួងអន្តោប្រវេសន៍ ដើម្បីពិនិត្យមើលជនបរទេស មានជនជាតិវៀតណាមជាដើម ដែលហូរចូលមកកម្ពុជាដោយខុសច្បាប់ ដែលមានចំនួនកាន់តែច្រើនឡើង ។ មួយទៀត គណបក្សណាដែលអង់អាចក្លាហានចោទមន្ត្រីអ្នកមានអំណាចបុណ្យស័ក្តិនិងទ្រព្យសម្បត្តិ ដែលរំលោភយកដីធ្លីរដ្ឋ និងដីប្រជាពលរដ្ឋមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន និងរៀបចំប្រព័ន្ធតុលាការឲ្យមានយុត្តិធម៌និងឯករាជ្យជាដើម គប្បីបោះឆ្នោតឲ្យគណបក្សនោះ ។

ប្រជាពលរដ្ឋខ្មែរខ្លួនឯងត្រូវទទួលខុសត្រូវចំពោះវាសនាប្រទេសកម្ពុជាតទៅមុខទៀត បើរើសអ្នកដឹកនាំមិនត្រឹមត្រូវ មិនត្រឹមតែពុំអាចបំបាត់ភាពក្រីក្របានទេ ថែមទាំងទឹកដីខ្មែរកាន់តែរួញតូចទៅៗ ហើយជនអន្តោប្រវេសន៍វៀតណាមចូលមកកម្ពុជាកាន់តែច្រើន ដោយគ្មានការត្រួតពិនិត្យ យូរទៅខ្មែរទៅជាជនជាតិភាគតិចនៅលើប្រទេសកំណើតរបស់ខ្លួន ។ ការព្រួយបារម្ភនេះមានជាទូទៅក្នុងចំណោមខ្មែរអ្នកស្នេហាជាតិ ទាំងក្នុងនិងក្រៅប្រទេស ជាពិសេសព្រួយបារម្ភចំពោះការបោះបង្គោលព្រំដែនរវាងកម្ពុជានិងវៀតណាម ដែលកំពុងអនុវត្តសព្វថ្ងៃនេះ ដោយអនុលោមតាមសន្ធិសញ្ញាខុសច្បាប់ឆ្នាំ១៩៨៥គឺខ្មែរត្រូវបាត់បង់ទឹកដី ។ ឆ្លងតាមការពិសោធន៍ចំនួន៣អាណត្តិនៃរាជរដ្ឋាភិបាលមកហើយ ប្រជាពលរដ្ឋខ្មែរល្មមយល់ដឹងគណបក្សណាមានលក្ខណៈបែបណាបានហើយ គឺត្រូវបោះឆ្នោតឲ្យគណបក្សណាដែលបំរើផលប្រយោជន៍ខ្មែរ ដូចបានពោលមកហើយ ។ ដើម្បីឲ្យជាតិខ្មែរបានសុខសន្តិភាព និងចំរើនលូតលាស់ខាងវប្បធម៌និងសេដ្ឋកិច្ច មុននឹងបោះឆ្នោតឲ្យគណបក្សណាមួយ ប្រជាពលរដ្ឋខ្មែរត្រូវពិនិត្យមើលឲ្យបានហ្មត់ចត់ល្អិតល្អន់ ព្រោះឆ្នោតមួយសន្លឹកអាចធ្វើឲ្យជាតិរស់និងឲ្យជាតិស្លាប់ ។ បានសេចក្តីថា ពុំមែនបោះឆ្នោតដោយសារប៊ីចេង២-៣ខាំ, ក្រមាមួយ, អង្ករ៨-១០គីឡូ ឬបោះឆ្នោតឲ្យដោយការភ័យខ្លាចការគំរាមកំហែងឡើយ តែត្រូវបោះឆ្នោតឲ្យគណបក្សណាមួយ ដោយការវិនិច្ឆ័យប្រកបដោយវិចារណញាណដ៏ត្រឹមត្រូវបំផុត ។៚

❀ ❀

❀